ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ០១៨០១៥ អពដ

# សេចក្តីណែនាំ

## ស្តីពីការអនុវត្តពន្ធកាត់ទុក ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល

អនុលោមតាមប្រកាសលេខ១១៦ សហវ.ប្រក ចុះថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការអនុវត្តកិច្ចព្រមព្រៀងស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល (Agreement for the Avoidance of Double Taxation and the Prevention of Fiscal Evasion with respect to Taxes on Income - DTA) រវាង÷

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះចៅស៊ុលតង់និងយ៉ាងឌីពើរតួន នៃប្រទេសព្រុយណេដារូសាឡឹម និង
- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ

និងដើម្បីសម្រួលក្នុងការអនុវត្តពន្ធកាត់ទុក ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការណែនាំដូចខាងក្រោម÷

១. អ្នកជាប់ពន្ធនិវាសនជនកម្ពុជា ត្រូវអនុវត្តតាមវិធីគណនេយ្យតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា លើរាល់ការទូទាត់ចំណូលជាភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវាបច្ចេកទេស ទៅអ្នកជាប់ពន្ធនិវាសនជននៃរដ្ឋភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។ ការទូទាត់ចំណូលខាងលើ ត្រូវចាត់ទុកថាបានទូទាត់ ប្រសិនបើបានកត់ត្រាក្នុងបញ្ជិកាគណនេយ្យរបស់អ្នកជាប់ពន្ធនិវាសនជនកម្ពុជាដែលជាភ្នាក់ងារកាត់ទុក។

២. តាមមាត្រាស្តីពីការចូលជាធរមាន នៃ DTA ពន្ធកាត់ទុកលើភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវាបច្ចេកទេស ត្រូវមានប្រសិទ្ធភាពអនុវត្តនៅប្រទេសប្រភព នៅពេលដែលប្រាក់ចំណូលកើតឡើង នៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។ សម្រាប់គោលដៅនៃពន្ធកាត់ទុកលើការបែងចែកភាគលាភ ប្រាក់ចំណូលកើតឡើងខាងលើ គឺជាប្រាក់ចំណូលដែលអ្នកជាប់ពន្ធនិវាសនជន បានទូទាត់ នៅថ្ងៃទីមួយនៃខែមករា ឬថ្ងៃបន្ទាប់ ក្នុងឆ្នាំប្រតិទិនបន្ទាប់ពីឆ្នាំដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

Collection by VCAT Professional Consultant

៣.	ការទូទាត់ចំណូលជាភាគលាភ ការប្រាក់ សួយសារ និងកម្រៃសេវាបច្ចេកទេស ត្រូវជាប់ពន្ធកាត់ទុកតាមមាត្រា ២៦ ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមិនឱ្យលើសពីអត្រាកំណត់នៅក្នុង DTA ដូចមានចែងក្នុងសេចក្តីណែនាំ លេខ ៤០៨៤ អពជ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់ថា អ្នកជាប់ពន្ធនិវាសនជនកម្ពុជា និងអ្នកជាប់ពន្ធនិវាសនជននៃរដ្ឋភាគីម្ខាងទៀត ស្ថាប័នរដ្ឋ និងអង្គការនានាដែលស្ថិតក្រោមវិសាលភាពនៃកិច្ចព្រមព្រៀងនេះ នឹងយកចិត្តទុកដាក់ចូលរួមអនុវត្តតាមខ្លឹមសារ នៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

Collection by VCAT Professional Consultant

ថ្ងៃ ព្រហស្បតិ៍ ០៥ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៨

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**